PESTECH RHB

**កម្មវិធីរ៉ូដស្ង (ROADSHOW) និងការធ្វើបរិវិសកម្មជាសាធារណៈ សម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈរបស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (“ផេសថិក (ខេមបូឌា)”) ឬ (“ក្រុមហ៊ុន”) ជាមួយនឹងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្នុងទីផ្សារគោលនៃផ្សារមូលបត្រកម្ពុជា**

យើងខ្ញុំមានកិត្តិយសសូមជម្រាបជូនដល់សាធារណៈជនថា ក្រុមហ៊ុនបានទទួលការអនុញ្ញាតជាស្ថាពរពីគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក**) សម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ និងបានចុះបញ្ជីជាស្ថាពរលើឯកសារផ្តល់ព័ត៌មាន នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០។

បង្កើតឡើងនៅឆ្នាំ២០១០ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ជាក្រុមហ៊ុនបច្ចេកវិទ្យាថាមពលអគ្គិសនី។ ក្រុមហ៊ុនផ្តល់សេវាកម្មចម្បងលើការផ្គត់ផ្គង់វិស្វកម្មប្រព័ន្ធថាមពលយ៉ាងទូលំទូលាយ និងដំណោះស្រាយបច្ចេកវិទ្យាសម្រាប់ការគូសប្លង់ លទ្ធកម្ម ការសាងសង់ ការដំឡើង និងការដាក់ឱ្យប្រើប្រាស់អនុស្ថានីយន៍ដែលមានតង់ស្យុងខ្ពស់និងតង់ស្យុងខ្ពស់ខ្លាំងនិងបណ្តាញបញ្ជូនដែលមាន តង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ក៏ដូចជាប្រព័ន្ធខ្សែភ្លើងក្រោមដីសម្រាប់ការបញ្ជូន និងចែកចាយអគ្គិសនី។ ក្រុមហ៊ុនក៏មានផ្តល់ សេវាកម្មក្នុងការប្រតិបត្តិការ និងការថែទាំប្រព័ន្ធបណ្តាញបញ្ជូន។ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ជាបុត្រសម្ព័ន្ធ ដែលត្រូវកាន់កាប់ទាំងស្រុងដោយ ក្រុមហ៊ុន PESTECH International Berhad ដែលបានចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោលនៃក្រុមហ៊ុន Bursa Malaysia Berhad ដែលជាប្រតិបត្តិករផ្សារភាគហ៊ុននៅប្រទេសម៉ាឡេស៊ី។

យើងខ្ញុំសូមគោរពអញ្ជើញដល់សាធារណៈជនផ្តល់កិត្តិយសក្នុងការចូលរួមក្នុងកម្មវិធីរ៉ូដស្ង សម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃចន្ទ ទី២៧ ខែកក្កដា ឆ្នាំ២០២០ តាមរយៈប្រព័ន្ធ Zoom។ សូមមើលព័ត៌មានលម្អិតនៃកម្មវិធីរ៉ូដស្ង និងការធ្វើបរិវិសកម្មជាសាធារណៈ សម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈខាងក្រោមនេះ៖

## ១. ព័ត៌មានលម្អិតនៃកម្មវិធីរ៉ូដស្ងជាសាធារណៈ:

- កាលបរិច្ឆេទ ៖ ថ្ងៃចន្ទ ទី២៧ ខែកក្កដា ឆ្នាំ២០២០
- ម៉ោង ៖ ៨:៣០ ព្រឹក - ១០:៤៥ ព្រឹក
- តាមរយៈ ៖ ប្រព័ន្ធវីដេអូ Conference (Zoom)

## ២. ការធ្វើបរិវិសកម្មជាសាធារណៈ និងគម្រោងពេលវេលាទុកនៃការបោះផ្សាយ*

- កាលបរិច្ឆេទចាប់ផ្តើមទទួលពាក្យស្នើសុំធ្វើបរិវិសកម្ម ៖ ម៉ោង ៨:០០ ព្រឹក ថ្ងៃចន្ទ ទី២៧ ខែកក្កដា ឆ្នាំ២០២០
- កាលបរិច្ឆេទឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្ម ៖ ម៉ោង ៤:៣០ រសៀល ថ្ងៃអង្គារ៍ ទី០៤ ខែសីហា ឆ្នាំ២០២០
- កាលបរិច្ឆេទបែងចែកមូលបត្រ ៖ ថ្ងៃសុក្រ ទី០៧ ខែសីហា ឆ្នាំ២០២០

## ៣. ព័ត៌មានការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ:

- ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈចំនួន ៣.៩៤៥.០០០ ភាគហ៊ុនមានសិទ្ធិបោះឆ្នោតថ្មីរបស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា)
- ក្នុងតម្លៃ ៣.១២០ រៀល ឬ ០,៧៦ ដុល្លារ ក្នុងមួយភាគហ៊ុន ដែលត្រូវបង់ឱ្យគ្រប់ចំនួនពេលដាក់ពាក្យស្នើសុំ។

សូមស្កេន QR Code ខាងក្រោមដើម្បីចុះឈ្មោះចូលរួមក្នុងកម្មវិធីរ៉ូដស្ង៖

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ក្រុមហ៊ុនធានាទិញមូលបត្រ អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក តាមរយៈទូរស័ព្ទលេខ ០២៣ ៩៦៩ ១៦១